ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Mar-2011, 15:05
CMS/CFO: Sann Rada

**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជជ
ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី
ដាក់ជូន៖ **អង្គជំនុំជម្រះសាលាដំបូង**
ភាសាដើម៖ បារាំង (បកប្រែខ្មែរ)
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៧ ខែមិនា ឆ្នាំ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស៖ **សាធារណៈ/Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖
ឈ្មោះមន្ត្រីកត់ត្រា៖
ហត្ថលេខា៖

---

**ចម្លើយតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណាររបស់ក្រុមភាគីការពារក្តីទាក់ទងនឹង អញ្ញត្រកម្មបឋម (វិធាន៨៩)**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ៖</u>**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

**<u>សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ៖</u>**

គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ជេត វណ្ណលី
ហុង គឹមសួន

**<u>ដាក់ជូន៖</u>**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**<u>ចំលងជូន ៖</u>**

**សហព្រះរាជអាជ្ញា ៖**

ឡោ ជុនធី

ស៊ីន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Silke STUDZINSKY
Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Madhev MOHAN
Barnabé NEKUIE
Lyma Thuy NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI

ជា លាង

Andrew CAYLEY

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**សហមេធាវីការពារក្តីជនជាប់ចោទ**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G.KARNAVAS

ផាត់ ពៅស៊ាង

Diana Ellis

ស ស្វវ៉ាន

Jacques VERGES
Philippe GRECIANO

## I. រំលឹកអង្គហេតុ និងនីតិវិធី

១. ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានសម្រេចបញ្ជូនខ្លួនជនជាប់ចោទទាំងបួនរូបទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (អ.ជ.ដ)[1]។

២. ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ[2]។

៣. ភាគីការពារក្ដីរបស់លោក នួន ជា បានដាក់បណ្ដឹងអញ្ញត្រកម្មបឋមចំនួនពីរផ្សេងគ្នានៅចំពោះមុខ អ.ជ.ដ[3]។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ អញ្ញត្រកម្មបឋមរួមបញ្ចូលគ្នាមួយផ្សេងទៀតក៏ត្រូវបានដាក់ដោយក្រុមនេះផងដែរ[4]។

៤. ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ភាគីការពាក្ដីឲ្យអ្នកស្រី អៀង ធីរិទ្ធ ក៏បានដាក់សារណាទាក់ទងនឹងអញ្ញត្រកម្មផងដែរ[5]។

៥. ភាគីការពារក្ដីរបស់លោក អៀង សារី ក៏បានដាក់សារណាទាក់ទងនឹងអញ្ញត្រកម្មផងដែរ[6]។

៦. ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ភាគីការពារក្ដីលោក ខៀវ សំផន ក៏បានដាក់សារណាទាក់ទងនឹងអញ្ញត្រកម្មជាឯកសារចំនួនពីរដាច់ដោយឡែកផងដែរ[7]។

---

1 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ D427/4/14, D427/1/26, D427/2/12។

2 ឯកសារ E9 ។

3 អញ្ញត្រកម្មនៃយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៨ កុម្ភៈ ២០១១ E36 និងអញ្ញត្រកម្មនៃទាក់ទងនឹងនិត្យានុកូលភាពនៃវិធានផ្ទៃក្នុង និងអនុភាពនៃដីការបស់ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ មករា ២០១១ E42។

4 ឯកសារ E51/3។

5 ឯកសារ E44។

6 ឯកសារ E43, E48។

7អញ្ញត្រកម្មនៃការរលត់បណ្ដឹងអាជ្ញា E47 និងអញ្ញត្រកម្មនៃយុត្តាធិការE46។

## II. សេចក្តីផ្តើម

៧. ដូច្នេះអនុលោមតាមវិធាន៨៩(២) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអ.វ.ត.ក សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការដាក់ចម្លើយតប ។

៨. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការឆ្លើយតបចំពោះអញ្ញត្រកម្មបឋមទាំងឡាយដែលលើកឡើងដោយភាគីការពារក្តីទាំងបួនក្រុម ។

## III. ឧឡឹករណ៍

៩. វិធាន ៨៩ នៃវិធានផ្ទៃក្នុងចែងថា៖

១. អញ្ញត្រកម្មទាក់ទងនឹង៖

ក. យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

ខ. ការរលត់បណ្តឹងអាជ្ញា

គ. មោឃភាពនីតិវិធីដែលត្រូវធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយត្រូវលើកឡើងយ៉ាងយូរ៣០ (សាមសិបថ្ងៃ) ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ។

២. អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់ឲ្យភាគីម្ខាងទៀតនូវឱកាសឆ្លើយតបនិងអញ្ញត្រកម្ម

៣.អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចជាបន្ទាន់បន្ទាប់អំពីអញ្ញត្រកម្មតាមសេចក្តីសម្រេចមួយដែលមានសំអាងហេតុ ឬនៅពេលជំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី។ នៅក្នុងករណីដែលអញ្ញត្រកម្មត្រូវបានសម្រេចក្នុងពេលជំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី កិច្ចដំណើការនិតិវិធីត្រូវធ្វើបន្ត ។

១០. ភាគីការពារក្តីជនជាប់ចោទទាំងបួនបានលើកឡើងនូវបណ្តាអញ្ញត្រកម្មដែលជំទាស់នឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ។

១១. ភាគីការពារក្តីទាំងនេះក៏បានលើកឡើងផងដែរនូវបណ្តាអញ្ញត្រកម្មទាក់ទងនឹងការផុតរលត់នូវបណ្តឹងអាជ្ញានៃការអនុវត្តបទប្បញ្ញត្តក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ស្តីអំពីបទឧក្រិដ្ឋដែលចែងដោយច្បាប់ជាតិ ក៏ដូចជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ។ ជាពិសេស

អញ្ញត្រកម្មនៃការផុតរលត់បណ្តឹងអាជ្ញាទាក់ទងនឹង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ខែសីហាឆ្នាំ១៩៤៩ ដែលបានលើកឡើងដោយភាគីការពារក្តីអៀងសារី ។

១២. ម្យ៉ាងវិញទៀត ភាគីអៀង សារី និងភាគីនួន ជា បានលើកនូវអញ្ញត្រកម្មនៃមោឃភាពទាក់ទងនឹងអ្វីដែលពួកគេចាត់ទុកថាជា« កិច្ចនីតិវិធី»ធ្វើក្រោយពីសេចក្តីសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ។

១៣. នៅគ្រប់ជ្រុងទាំងអស់ បើទោះជាខ្លឹមសារនៃការលើកឡើងទាំងនោះផ្តុកទៅដោយបញ្ហាស្រពេចស្រពិលយ៉ាងណាក៏ដោយ ក៏វាបានបង្ហាញយ៉ាងច្បាស់ក្រឡែតអំពីសារណារបស់ភាគីការពារក្តីនីមួយៗថា ពួកគេគាំទ្រនូវភាពចាំបាច់ចំពោះអង្គជំនុំជម្រះដើម្បីធ្វើការអនុវត្តនូវច្បាប់ជាតិកម្ពុជា (ក្រមព្រហ្មទណ្ឌ១៩៥៦) ដែលនៅជាធរមានក្នុងអំឡុងពេលនៃហេតុការណ៍ប្រព្រឹត្តឡើងក្នុងរបបខ្មែរក្រហម ។ ពួកគេក៏បានលើកឡើងផងដែរថា ការពិចារណានូវបទឧក្រិដ្ឋអន្តរជាតិ ត្រូវស្របជាមួយនឹងគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនៃអំឡុងពេល និងគោរពទៅតាមគោលការណ៍និត្យានុកូលភាពតែប៉ុណ្ណោះ ហើយចំពោះអំពើទាំងនោះប្រហែលមិនត្រូវបានចែងដោយជាក់លាក់ថាជាបទល្មើសព្រហ្មទណ្ឌនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌនៅក្នុងសម័យកាលនោះទេ ។ យោងតាមហេតុផលតក្កៈរបស់ពួកគេ ដូច្នេះអ្វីៗដែលកើតក្រោយពេលនេះត្រូវផុតរលត់នូវបណ្តឹងអាជ្ញាតាមរយៈការអនុវត្តនូវអាជ្ញាយុកាល១០ឆ្នាំ ដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ។ ចុងបញ្ចប់ ភាគីអៀង សារី និងភាគីនួន ជា បានស្នើសុំមោឃភាពនៃកិច្ចនីតិវិធីដែលចេញដោយអ.ជ.ជ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ។ ក្នុងពេលជាមួយគ្នានេះផងដែរ ភាគីនួន ជា ក៏បានលើកឡើងពីអញ្ញត្រកម្មទាក់ទងនឹងអនិត្យានុកូលភាពនៃវិធានផ្ទៃក្នុងដែលក៏នឹងត្រូវតែសម្រេចដោយអង្គជំនុំជម្រះនេះផងដែរ ។

១៤. ជំហានដំបូង ជាបញ្ហាចម្បង មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងអំពីភាពគ្មានយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដោះស្រាយនូវបញ្ហាដែលស្ថិតនៅក្នុងដែនសេចក្តីសម្រេចរបស់ខ្លួន ក៏ដូចជាភាពមិនអាចទទួលយកបាននូវបណ្តាបញ្ហាផ្សេងៗដែលលើកឡើងនៅក្នុងសារណាខាងលើនោះដែរ ។

១៥. ជំហានទី២ ជាបញ្ហាបន្ទាប់បន្សំ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការឆ្លើយតបជារួមតែមួយសម្រាប់ចំនុចផ្សេងៗគ្នាទាំងឡាយដែលពង្រីកដោយក្រុមការពារក្តីជនជាប់ចោទទាំងបួន ។

## ក- មូលដ្ឋានទី១ (បញ្ហាចម្បង) ភាពមិនអាចទទួលបាននៃការស្នើសុំ

### ១. អំពីការអះអាងនៃភាពគ្មានយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

១៦. អង្គជំនុំជម្រះផ្សេងៗរបស់អ.វ.ត.ក បានសម្រេចជាច្រើនដង និងមានភាពច្បាស់លាស់គ្រប់គ្រាន់ក្នុងការដោះស្រាយបណ្ដាចំណោទបញ្ហានៃអញ្ញត្រកម្មទាក់ទងនឹងសមត្ថកិច្ចរបស់អ.វ.ត.ក ហើយជាវិបាកនោះក៏បានដោះស្រាយបញ្ហានៃការផុតរលត់បណ្ដឹងអាជ្ញានៃបទល្មើសថ្នាក់ជាតិផងដែរ។

១៧. នៅក្នុងសំនុំរឿង០០១ (ករណីឌុច) អង្គជំនុំជម្រះសាលាដំបូងបានវិនិច្ឆ័យយ៉ាងច្បាស់ក្រឡែតអំពីអញ្ញត្រកម្មនៃយុត្តាធិការ ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូង ក៏បានវិនិច្ឆ័យអំពីបញ្ហាទាក់ទងនឹងការរំលោភបំពានលើគោលការណ៍និត្យានុកូលភាពផងដែរ ។ ជាមួយគ្នានេះផងដែរ នៅក្នុងសំនុំរឿង០០២ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចចំពោះបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីការបញ្ជូនរឿងទៅជំនុំជម្រះរបស់ភាគីនួនជា និងអៀង ធីរិទ្ធ ។ អង្គបុរេជំនុំជម្រះក៏បានអះអាងពីសមត្ថកិច្ចរបស់អ.វ.ត.កក្នុងការវិនិច្ឆ័យជនជាប់ចោទទាំងបួនដោយយោងតាមពីមាត្រា៣ ដល់មាត្រា៦ នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក។[8]

១៨. ជាថ្មីម្ដងទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ការស្នើសុំចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចយុត្តាធិការដែលលើកឡើងដោយបណ្ដាភាគីការពារក្ដីនឹងត្រូវប្រកាសថាមិនអាចទទួលយកបាន ដោយសំអាងមូលហេតុនៃការរំលោភលើគោលការណ៍« ne bis in idem » (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអំពើដដែល)។ ការពិត ទាក់ទងនឹងអញ្ញត្រកម្មនៃយុត្តាធិការ បណ្ដាក្រុមភាគីការពារក្ដីអៀង ធីរិទ្ធ អៀង សារី និងនួន ជា បានលើកឡើងយ៉ាងច្បាស់ក្រឡែតនូវអញ្ញត្រកម្មនៃសមត្ថកិច្ចយុត្តាធិការនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលបានសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតដោយផ្អែកលើមូលដ្ឋាន វិធាន៦៨ និង៧៤ ។ ជាការពិតដែលថាវិធាន ៨៩(១)បានចែងថាភាគីអាចលើកឡើងអំពីអញ្ញត្រកម្មនៃយុត្តាធិការ ប៉ុន្តែអំណាននៃបទប្បញ្ញត្តនេះត្រូវអានស្របគ្នាជាមួយនឹងបទប្បញ្ញត្តនៃវិធាន៧៧(១៣) ដែលបានចែងថា រាល់សេចក្ដីសម្រេចដែលចេញដោយអង្គបុរេជំនុំ

---

8សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីការបញ្ជូនរឿងទៅជំនុំជម្រះរបស់ភាគីនួនជា និងអៀង ធីរិទ្ធ នៃសំនុំរឿង០០២ ចុះថ្ងៃទី១៥ កុម្ភៈ ២០០១ (D427/3/15)។

ជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ចំពោះសហចៅក្រមស៊ើបអង្កេតជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។ ដូចករណីមិនត្រូវលើកឡើងទៀតដូចដែលជនជាប់ចោទធ្លាប់បង្ហាញ ល្អិកណា អង្គបុរេជំនុំជម្រះបានវិនិច្ឆ័យរួចហើយចំពោះឧទ្ធរណ៍ស្តីពីបញ្ហាយុត្តាធិការ គេមិនអាចនឹងលើកយកបញ្ហាយុត្តាធិការ

នេះមកចោទជាថ្មីម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ ។

១៩. យោងតាមគោលការណ៍នៃបទប្បញ្ញត្តិពិសេសបដិប្បញ្ញត្តិចំពោះបទប្បញ្ញត្តទូទៅ (*specialia generalibus derogant*) ដូច្នេះ ចំណោទនៃយុត្តាធិការដែលបានសម្រេចដោយអង្គបុរេជំនុំជម្រះដោយផ្អែកតាមវិធាន៧៤ និង៧៧(១៣) មិនអាចលើកយកមកពិចារណាជាថ្មីម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយមិនគិតថាឧទ្ធរណ៍លេចចេញពីបញ្ហានៃយុត្តាធិការនោះទៀតទេ ។ ដោយពិចារណ៍លើមូលដ្ឋានេះ និងដោយមិនអាចចៀសវាងបានអង្គជំនុំជម្រះសាលាដំបូងត្រូវរក្សាឲ្យបានច្បាស់លាស់នូវនិរន្តភាពរបស់គោលការណ៍នៃវិធាន៧៧ (១៣) ទាក់ទងនឹងចរិតលក្ខណៈស្ថាពរនៃបណ្តាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត។ ក្នុងករណីនេះ គោលការណ៍នៃបទប្បញ្ញត្តិពិសេសបដិប្បញ្ញត្តិចំពោះបទប្បញ្ញត្តទូទៅត្រូវបានអនុវត្ត ។ ដូច្នេះជាវិបាក វិធាន៧៧(១៣)ដែលជាវិធានពិសេសនោះធ្វើបដិប្បញ្ញត្តលើវិធានទូទៅ៨៩ ។

២០. គឺនៅក្នុងដំណាក់កាលនីតិវិធីនេះហើយ អង្គជំនុំជម្រះសាលាដំបូងមិនអាចក្លាយជាអង្គជំនុំជម្រះឧទ្ធរណ៍ដើម្បីពិចារណាជាថ្មីលើចំណោទបញ្ហាដែលបានសម្រេចរួចហើយជាឧទ្ធរណ៍នូវដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដោយអង្គបុរេជំនុំជម្រះនោះទេ ។

២១. ជារួមមក សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះសាលាដំបូងប្រកាសភាពគ្មានសមត្ថកិច្ចក្នុងការវិនិច្ឆ័យនូវបញ្ហាដែលបានលើកឡើងខាងលើទាក់ទងនឹងអញ្ញាត្រកម្មនៃយុត្តាធិការ និងអញ្ញាត្រកម្មនៃការផុតរលត់បណ្តឹងអាជ្ញាសម្រាប់បទល្មើសជាតិ ដោយមូលហេតុថាវាត្រូវបានសម្រេចក្នុងលក្ខណៈឧទ្ធរណ៍រួចហើយដោយអង្គបុរេជំនុំជម្រះ ។ ដូចនេះការស្នើសុំទាំងនោះគឺជាការរំលោភបំពានលើវិធាន ៧៧(១៣) ។

២២. ចំពោះរាល់ការស្នើសុំទាំងឡាយណាដែលទាញដាក់ឲ្យអង្គជំនុំជម្រះសាលាដំបូងនេះពិចារណាលើបណ្តាអញ្ញាត្រកម្មបឋមទាំងនោះមុននឹងការសម្រេចលើអង្គសេចក្តី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

សន្និដ្ឋានថាវាគ្មានមូលដ្ឋានគតិយុត្តណាមួយសោះចាប់បង្ខំឲ្យស្ថាប័នយុត្តាធិការ ហើយជាពិសេសឲ្យអ.វ.ត.ក ចាំបាច់មិនត្រូវសម្រេចដំណាលគ្នានូវអញ្ញត្រកម្មបឋម និងអង្គសេចក្ដីនោះទេ។ វិធានផ្ទៃក្នុងបានទុកបញ្ហានេះជាការពិចារណាផ្ដាច់មុខរបស់ចៅក្រម ។ ដោយអនុវត្តតាមវិធាន ៨៩(៣) នៅគ្រប់ករណីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាដំណាលគ្នានូវរាល់អញ្ញត្រកម្មជាមួយនឹងការសម្រេចលើអង្គសេចក្ដី ។ តាមរយៈការឆ្លុះបញ្ចាំងនៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងអាចអនុវត្តគោលការណ៍ដូចគ្នានេះបាន ។

២. ការមិនអាចទទួលយកបាននៃការស្នើសុំដោយសារការរំលោភលើគោលការណ៍ NE BIS IN IDEM (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអំពើដដែល)

២៣. នៅក្នុងករណីដែល អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថាខ្លួនមានសមត្ថកិច្ចដើម្បីពិចារណាលើអញ្ញត្រកម្មទាំងនេះ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានស្នើឲ្យអង្គជំនុំជម្រះប្រកាសពីភាពមិនអាចទទួលបាននៃបណ្ដាការស្នើសុំនេះ ដោយសារការរំលោភលើគោលការណ៍ទូទៅនៃច្បាប់« ne bis in idem » ព្រមទាំងរំលោភបំពានលើអាជ្ញាអស់ជំនុំដែល « res judicata »។

២៤. ការអនុវត្តបញ្ចូលគ្នានៃគោលការណ៍ទាំងពីរនេះនាំឲ្យអង្គយុត្តាធិការមួយមិនអាចវិនិច្ឆ័យជាថ្មីនូវបញ្ហាដែលខ្លួនបានចេញសេចក្ដីសម្រេចរួចមកហើយ ហើយជាពិសេសនៅក្នុងសំនុំរឿងព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំជំទាស់រាល់ភាគីទាំងអស់(erga omnes) ។ នេះដោយសារវាមានចរិតជាសណ្ដាប់ធ្នាប់សាធារណៈ ។

២៥. នៅក្នុងស្ថានភាពនេះ ចំពោះបណ្ដាភាគីជនជាប់ចោទទាំងអស់ដែលបានពាំនាំនូវទឡ្ហីករណ៍ដដែលៗ ប៉ុន្តែត្រូវបានលើកឡើងក្នុងទម្រង់ផ្សេងៗ អង្គជំនុំជម្រះសាលាដំបូងអាចនឹងធ្វើការបញ្ជាក់ប្រកបដោយប្រសិទ្ធិភាពម្ដងទៀតជារួមតែម្ដងដើម្បីបញ្ជាក់ពីអសមត្ថកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងមូលដ្ឋាននៃគោលការណ៍និត្យានុកូលភាពក៏ដូចជាគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។ ហើយម្យ៉ាងទៀតក៏នឹងបញ្ជាក់អំពីរឿងនៃការផុតរលត់បណ្ដឹងអាជ្ញាផងដែរ។ ផ្ទុយទៅវិញ គេអាចធ្វើការគូសបញ្ជាក់ឲ្យកាន់តែទូលំទូលាយតែម្ដងថានៅគ្រប់បញ្ហាទាំងអស់ ដែលថាគ្រប់បណ្ដាអង្គជំនុំជម្រះនៃអ.វ.ត.ក បានប្រកាន់នូវជំហរមួយច្បាស់ និងមិនអាចលើកមកតវ៉ាទៀតទេ។ វៀរលែងតែបញ្ហាមោឃភាពនៃកិច្ចនីតិវិធីចេញ ចំពោះក្របខណ្ឌនៃអញ្ញត្រកម្មបឋមដែលទាញចេញពីវិធាន ៨៩(១)

គ្រប់គ្រងតែលើបណ្ដាអញ្ញត្រកម្មទាក់ទងនឹងសមត្ថកិច្ចយុត្តាធិការឬការផុតរលត់នៃបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

២៦. ជាវិបាក អង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ជាក់ជាថ្មីថាសំអាងដដែលនឹងប្រាកដជាធ្វើឲ្យលេចនូវលទ្ធផលដដែល ។ ហើយតាមរយៈលទ្ធផលនេះ អ.វ.ត.កបានធ្វើការវិនិច្ឆ័យជាច្រើនលើកមកហើយ ។ អង្គជំនុំជំរះត្រូវធ្វើការបដិសេធនូវគ្រប់ការស្នើសុំទាំងអស់របស់ភាគីការពារក្ដី និងសម្រេចថាការស្នើសុំទាំងអស់នេះមិនអាចទទួលយកបានដោយសារវាបានរំលោភបំពានលើគោលការណ៍ ne bis in idem និងរំលោភបំពានលើគោលការណ៍នៃអាជ្ញាអស់ជំនុំ res judicata ។

២៧. ស្របជាមួយនឹងនេះដែរ ទឡ្ហីករណ៍ស្តីអំពីភាពគ្មានយុត្តាធិការនៃអ.វ.ត.កត្រូវបានសម្រេចរួចម្តងមកហើយដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំនុំរឿង០០១ (សំនុំរឿងឌុច) ។

២៨. ចំពោះសំនុំរឿងនេះស្របតាមវិធាន ៦៨ និងវិធាន៧៤ លោកនួន ជា[9] និងអ្នកស្រី អៀង ធីរិទ្ធិ[10] បានលើកនូវចំណោទអំពីភាពគ្មានយុត្តាធិការនៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីការដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត[11] ។ អង្គបុរេជំនុំជម្រះបានសម្រេចករណីនេះទៀតនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ [12]។

២៩. នៅក្នុងគំនិតនេះដដែល ចំពោះបញ្ហាបទក្រិដ្ឋថ្នាក់ជាតិ នៅក្នុងសំនុំរឿងឌុច អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា បទឧក្រិដ្ឋទារុណកម្ម និងការសម្លាប់ ដែលមានចែងនៅក្នុងច្បាប់ជាតិកម្ពុជានោះ ក៏ត្រូវបានបញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[13] ។

៣០. នៅក្នុងសំនុំរឿង០០២ នៅក្នុងសេចក្តីសម្រេចទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់អៀងសារី អង្គបុរេជំនុំជម្រះបានទាត់ចោលទឡ្ហីករណ៍របស់ជនជាប់ចោទចោលដែលថា «សហចៅក្រមស៊ើបអង្កេត

---

9 សារណាឧទ្ធរណ៍របស់ភាគីនួនជា 18 តុលា 2010 ។

10 សារណាឧទ្ធរណ៍របស់ភាគីអៀង ធីរិទ្ធ 18 តុលា 20។10

11 ដីការដំនោះស្រាយ ១៦ កញ្ញា ២០១០។

12 ឯកសារ D427/3/15, កថាខណ្ឌ87-167។

13 សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសំនុំរឿងឌុច កថាខណ្ឌ 107។

មានការភន្តច្រលំផ្នែកច្បាប់ដោយយល់ថា អ.វ.ត.ក មានយុត្តាធិការសម្រេចលើបណ្តាបទឧក្រិដ្ឋដែលចែងក្នុងមាត្រា៣ថ្មី (បទឧក្រិដ្ឋដែលចែងនៅក្នុងច្បាប់ជាតិកម្ពុជា) [14] » ។ អង្គបុរេបានរក្សាទុកជំហរដដែលទាក់ទងនឹងបញ្ហានេះដូចគ្នាទៅនឹងសេចក្តីសម្រេចចំពោះបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ[15] របស់នួន ជា និង អៀង ធីរិទ្ធ ។

៣១. ខុសពីជនជាប់ចោទដទៃទៀត ខៀវ សំផនមិនបានលើកឡើងនូវបញ្ហានៃយុត្តាធិការនិងការរលត់នៃបណ្តឹងអាជ្ញានៅក្នុងសារណាឧទ្ធរណ៍ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ ដោយផ្អែកលើហេតុផលលើកឡើងខាងលើ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានស្នើអង្គជំនុំជម្រះសាលាដំបូងប្រកាសពីការមិនអាចទទួលយកបាននូវការស្នើសុំនេះ ដោយយោងសំអាងនៃភាពគ្មានសមត្ថកិច្ចយុត្តាធិការនិងការមិនគោរពនូវគោលការណ៍ *ne bis in idem* ។

### ៣. ការមិនអាចទទួលបាននៃការស្នើសុំដែលលេចចេញក្រៅអំពីក្របខណ្ឌចែងដោយវិធាន ៨៩ (១)

៣២. ក្របខណ្ឌអញ្ញត្រកម្មបឋមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងត្រូវបានចែងដោយវិធាន ៨៩ (១)។ ជាមួយគ្នាផងដែរ គ្រប់បញ្ហាទាំងអស់ទាក់ទងនឹងអញ្ញត្រកម្មបឋម ដែលមិនជាប់ពាក់ពន្ធនឹងយុត្តាធិការ ការផុតរលត់បណ្តឹងអាជ្ញា មោឃភាពនៃកិច្ចនីតិវិធី ដែលចេញផុតពីក្របខណ្ឌចែងដោយវិធាននេះ និងត្រូវតែប្រកាសថាមិនអាចទទួលបាន ។

៣៣. ពោះគ្រប់ការស្នើសុំដែលចង់ឲ្យអង្គជំនុំជម្រះធ្វើការពិចារណាលើគ្រប់អញ្ញត្រកម្មបឋមទាំងនេះមុននឹងការសម្រេចលើអង្គសេចក្តីនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមសន្និដ្ឋានថាវាគ្មានមូលដ្ឋានគតិយុត្តណាមួយទាល់តែសោះដែលកំណត់ជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ហើយជាពិសេសចំពោះអ.វ.ត.ក ឲ្យសម្រេចក្នុងអង្គសេចក្តីជាមួយនឹងអញ្ញត្រកម្មបឋមនោះ។ ដោយអនុវត្តតាមវិធាន ៨៩(៣)អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចគ្រប់ករណីអញ្ញត្រកម្មបឋមដំណាលនឹងការ

---

14 សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់អៀងសារីជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ D427/1/26។

15 ឯកសារ D427/3/15, កថាខណ្ឌ168-184។

សម្រេចលើអង្គសេចក្តី នៅគ្រប់ករណីទាំងអស់។ ហើយតាមរយៈសំនុំរឿង០០១ អង្គជំនុំជម្រះ អាចអនុវត្តគោលការណ៍ដូចគ្នានេះដែរ ។

**ខ- មធ្យោបាយទីពីរ (ផ្នែកបន្ទាប់បន្សំ)៖ ទៅលើអង្គសេចក្តី**

៣៤. ដូចដែលមានការអភិវឌ្ឍតាំងពីពេលមុនរួចមកហើយ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ក្រប

ខ័ណ្ឌនៃអញ្ញត្រកម្មបឋមត្រូវបានឲ្យនិយមន័យយ៉ាងច្បាស់ដោយវិធាន៨៩ (១) តាមរយៈបញ្ញត្តិនេះ អញ្ញត្រកម្មបឋមបានកំណត់យ៉ាងច្បាស់លាស់ទាក់ទងនឹងបញ្ហាមួយចំនួន ដូចជាយុត្តាធិការរបស់ អ.វ.ត.ក.(១) និង ការផុតរលត់នៃបណ្តឹងអាជ្ញា (២)។

៣៥. ដើមបណ្តឹងរដ្ឋប្បវេណីមានបំណងយកបញ្ហាទាំងនេះទល់នឹង បណ្តាសេចក្តីសម្រេចរបស់ អ.វ.ត.ក. ដែលមានភាពច្បាស់លាស់ និង មានសម្អាងហេតុគ្រប់គ្រាន់ដើម្បីឆ្លើយតបចំពោះ ទិដ្ឋភាពដែលលើកឡើងដោយភាគីជនចោទ។

**១. ទឡ្ហីករណ៍ទីមួយ : យុត្តាធិការរបស់អង្គជំនុំជម្រះ (ការរំលោភលើ គោលការណ៍នីត្យានុកូលភាព)**

៣៦. ដោយមើលឃើញថា មានការរំលោភទៅលើគោលការណ៍នីត្យានុកូលភាព ទាក់ទងនឹង យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីចេញសេចក្តីសម្រេច ទៅលើបណ្តាឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរ**លើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩**) អង្គបុរេជំនុំជម្រះតាមរយៈ សេចក្តីសម្រេចរបស់ខ្លួន ទៅលើបណ្តឹងឧទ្ធរណ៍ដែលបានប្តឹងដោយ នួន ជា និង អៀង ធីរិទ្ធ បានចេញសេចក្តី សម្រេចនៅថ្ងៃទី១៥ កុម្ភៈ ២០១១ (មើលកថាខ័ណ្ឌ៩៧ ដល់ ១០០)។ បុរេអង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចយ៉ាងច្បាស់ថា មិនមានកាតព្វកិច្ចគតិយុត្តណាមួយដែលដាក់បង្ខំ ជាសមត្ថកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យជាដំបូងនៃ គោលការណ៍នីត្យានុកូលភាពនៃនីតិជាតិក្នុងប្រទេសកម្ពុជា។

៣៧. ភាពច្បាស់លាស់បានលេចឡើងតាមរយៈកថាខ័ណ្ឌ៩៩ អង្គជំនុំជម្រះ បានចេញសេចក្តី សម្រេចថា អ.វ.ត.ក មានសមត្ថកិច្ចក្នុងការកាត់សេចក្តីទៅលើបទឧក្រិដ្ឋដែលមានចែងនៅក្នុងច្បាប់អ.វ.ត.ក. ហើយអង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការគោរពគោលការណ៍នីត្យានុ កូលភាពអន្តរជាតិ[16]។

៣៨. គោលការណ៍នេះ មិនបានទាមទារថា ឧក្រិដ្ឋកម្មអន្តរជាតិ និង ទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអនុវត្តនៅក្នុងច្បាប់ជាតិ ដើម្បីអាចកំណត់នូវទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ចារីនៃ ឧក្រិដ្ឋកម្មទាំងនេះ។ អង្គហេតុដែលប្រទេសកម្ពុជាបានជ្រើសរើសប្រព័ន្ធនៃការប្រើប្រាស់ច្បាប់អន្តរជាតិដោយផ្ទាល់ (Moniste) ឬ ការប្រើប្រាស់ច្បាប់អន្តរជាតិដោយប្រយោល (dualiste) មិនមែនជាឧបសគ្គរាំងដល់សុពលភាពនៃបទបញ្ញត្តិដែល ត្រូវយកមកអនុវត្ត នៅក្នុង អ.វ.ត.ក ឡើយ[17]។

### ១.១. អំពើប្រល័យពូជសាសន៍ និង ការបំពារបំពានធ្ងន់ធ្ងរលើ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ :

៣៩. ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ អង្គបុរេជំនុំជម្រះបានលើកឡើងថា ក្នុងអំឡុងពេលនៃអំពើប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យ ពូជសាសន៍ និង ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាផ្នែកមួយនៃនីតិអន្តរជាតិ។ ដូចនេះ អ.វ.ត.ក មានសមត្ថកិច្ចក្នុងការកាត់សេចក្តីទៅលើជនត្រូវចោទចំពោះការរំលោភ ដែលមាននៅក្នុងសន្ធិសញ្ញា ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ការបំពារបំពានធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវ ១៩៤៩[18]។

### ១.២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ :

៤០. អង្គបុរេជំនុំជម្រះ បានចាត់ទុកថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានចែង នៅក្នុងគោលការណ៍ណ្យូរមប៊ែរ (Nuremberg) ដែលជាផ្នែកមួយនៃនីតិទំនៀមទម្លាប់អន្តរជាតិ គឺមាន

---

[16] មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីនីតិរដ្ឋប្បវេណី និង នយោបាយ ជាពិសេស វាក្យខ័ណ្ឌ២។

[17] ឯកសារយុត្តាធិការ D427/3/15 ចុងបញ្ចប់នៃកថាខ័ណ្ឌ ៩៨។

[18] ឯកសារយុត្តាធិការ D427/3/15 កថាខ័ណ្ឌ ១២៥។

ភាពច្បាស់លាស់គ្រប់គ្រាន់នៅក្នុងអំឡុងរបបខ្មែរក្រហម។ អង្គបុរេជំនុំជម្រះបានអះអាងថា ឧក្រិដ្ឋកម្មនេះគឺអាចគ្រោងទុកជាមុន និង ជនត្រូវចោទអាចដឹងក្នុងអំឡុងនៃការប្រព្រឹត្តអំពើទាំងនេះ[19]។

### ១.៣. ទំនួលខុសត្រូវរបស់ថ្នាក់លើ :

៤១. នៅក្នុងកថាខ័ណ្ឌ ២៣២ នៃសេចក្ដីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះបានធ្វើការចង្អុលបង្ហាញយ៉ាងច្បាស់ថាទ្រឹស្ដីនៃការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ គឺជាផ្នែកមួយនៃនីតិ ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩។ ហើយទម្រង់នៃការទទួលខុសត្រូវនេះ គឺអាចគ្រោងទុកជាមុន និង អាចចូលទៅដល់ជនត្រូវចោទបាន ក្នុងអំឡុងនៃការប្រព្រឹត្តអង្គហេតុទាំងនេះ។

### ១.៤. សហកម្មឧក្រិដ្ឋកម្មរួម :

៤២. សហចៅក្រមស៊ើបសួរបានរំលឹកថា សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងនីតិអន្តរជាតិ គឺជាទម្រង់នៃ ការទទួលខុសត្រូវលក្ខណៈជាបុគ្គល ដែលបានប្រព្រឹត្ត[20]។ ដើម្បីឲ្យមានការប្រើប្រាស់នៃទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ចាំបាច់ណាស់ដែលត្រូវមានលក្ខខ័ណ្ឌ៣ រួមគ្នា ៖

១. សហកម្មឧក្រិដ្ឋកម្មរួម ត្រូវតែមានចែងនៅក្នុងបទបញ្ញត្តិរបស់អ.វ.ត.ក. ទោះ ដោយច្បាស់ ឬ មិនច្បាស់ក៏ដោយ

២. សហកម្មឧក្រិដ្ឋកម្មរួម ត្រូវតែមាននៅក្នុងនីតិទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលនៃអង្គហេតុ

៣. បទបញ្ញត្តិដែលបានចែងនៅក្នុងទម្រង់ទំនួលខុសត្រូវនេះ ត្រូវតែច្បាស់លាស់ ថាអាចដាក់ពិរុទ្ធទៅលើជនជាប់ចោទ

៤. ជនជាប់ចោទត្រូវតែស្ថិតក្នុងវិធានការដែលអាចដឹងទំនួលខុសត្រូវនេះជាយថាហេតុ។

៤៣. មាត្រា២៩ នៃច្បាប់សេចក្ដីពីការបង្កើតអ.វ.ត.ក. ចែងអំពីការទទួលខុសត្រូវជាបុគ្គលចំពោះ «ជនសង្ស័យណាមួយ ដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ដែលបានជួយ ឬ បាន ប្រព្រឹត្តឧក្រិដ្ឋ

[19] ឯកសារយុត្តាធិការ D427/3/15 ចុងបញ្ចប់នៃកថាខ័ណ្ឌ ១៣៣។

[20] ដីកាដំណោះស្រាយ ថ្ងៃទី១៦ កញ្ញា ២០១០ ករណី ០០២។

កម្មដែលត្រូវបង្ក្រាបដោយយុត្តាធិការ»។ សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់នៃការទទួលខុសត្រូវ គឺត្រូវបានឲ្យនិយមន័យផងដែរនៅក្នុងនីតិអន្តរជាតិក្នុងដំណាក់កាលសំណុំរឿងដែលត្រូវបានរៀបចំឡើងបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ។ នេះគឺជាសំនុំរឿងឧក្រិដ្ឋកម្មសង្គ្រាមដ៏ធំដែលត្រូវបានលើកឡើងនៅចំពោះមុខតុលាការយោធា[21] ណូរមប៊ែរ (Nuremberg)(ដែលតាមរយៈនេះត្រូវបានគេបញ្ជាក់យ៉ាងច្បាស់ថា អង្គហេតុដែលបានកើតឡើងស្របពេលដែលសន្ធិសញ្ញាមិនបានចែងអំពីទោស ដើម្បីផ្តន្ទាទោសពិរុទ្ធជននៃបទល្មើស មិនមែនជាឧបសគ្គក្នុងការកំណត់ការទទួលខុសត្រូវលក្ខណៈជាបុគ្គលនោះទេ)។

៤៤. ធម្មនុញ្ញណូរមប៊ែរ (Nuremberg) ច្បាប់លេខ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យតុលាការយោធា

អន្តរជាតិសម្រាប់ចុងបូព៌ា បានទទួលស្គាល់ផងដែរនូវលទ្ធភាពក្នុងការដាក់ បទចោទទៅលើបុគ្គលដែលបានចូលរួម ឬ ការចូលរួមផ្សំគំនិតដើម្បីសម្រេចនូវគោលបំនងឧក្រិដ្ឋកម្ម។

៤៥. យុត្តិសាស្ត្រដ៏ធំមួយ ដែលបានបញ្ចូលសញ្ញាណទាំងនេះ ហើយជាបន្តបន្ទាប់ត្រូវបានអភិវឌ្ឍន៍ ដូចជានៅប្រទេសបារាំង អង់គ្លេស និង ប្រទេសអាមេរិច[22]។

៤៦. បន្ទាប់មកទៀត ទស្សនៈទាំងនេះដែលបានអនុវត្តជាអន្តរជាតិ ត្រូវបានធ្វើឲ្យជាក់ច្បាស់ដោយតុលាការអន្តរជាតិសម្រាប់ អតីតយូហ្គូស្លាវី។

៤៧. ដូច្នេះ វាការពិតណាស់ថា ទស្សនាទាននៃការប្រព្រឹត្តរួមដើម្បីសម្រេចឲ្យបានឧក្រិដ្ឋកម្ម ឬ ការប្រព្រឹត្តខុសច្បាប់ ដោយមានការចូលរួមយ៉ាងសកម្មក្នុងគម្រោង ឬ ការផ្សំគំនិតក្នុង ឧក្រិដ្ឋកម្ម ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយមុនពេលការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបាន ធ្វើបទចោទទៅលើអ្នកដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៤៨. ជាចុងបញ្ចប់ ទម្រង់ដាច់ដោយឡែកនៃការទទួលខុសត្រូវដែលបានចែងនៅក្នុងមាត្រា ២៩ (ថ្មី) គឺត្រូវបានទទួលស្គាល់ដោយក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ លើកលែងតែរបៀបនៃការចូលរួមដោយការមានផែនការ និង ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ[23]។ សញ្ញាណរបស់ការ

[21] ណូរមប៊ែរ ថ្ងៃទី ១៤ វិច្ឆិកា ១៩៤៥ ដល់ ១ តុលា ១៩៤៦ អត្ថបទជាផ្លូវការ កំរិត XLII តុម១ ទំព័រ ២៣២ ដល់ ២៤៣។

[22] មើលសារណាស្តីអំពី អាមីគូស គួរីយ៉េ របស់សាស្ត្រាចារ្យ អង់តូនីយ៉ូ កាសីស ថ្ងៃទី២៧ តុលា ២០០៨ D99/3/24។

[23] មើលសេចក្តីសម្រេចរបស់ឌុច កថាខ័ណ្ឌ ៤៧៥។

រៀបចំផែនការបានរកឃើញនៅក្នុងបណ្តាបទបញ្ញត្តិជាក់លាក់នៃក្រមនេះផងដែរ ហើយអង្គហេតុនេះគឺមានគម្រោងទុកជាមុន ដែលរាល់កិច្ចដែលបានកើតឡើង អាចបង្កើតឲ្យមានឧក្រិដ្ឋកម្ម។

៤៩. ដើម្បីឲ្យកាន់តែច្បាស់ទៅទៀតនោះ គឺករណី ខៀវ សំផន តាមរយៈកថាខ័ណ្ឌ២៩ នៅក្នុងការស្នើសុំរបស់គាត់ ទាក់ទងនឹងអញ្ញត្រកម្មបឋមដែលផ្តោតសំខាន់ទៅលើសមត្ថកិច្ចរបស់ អ.វ.ត.ក. ដែលបានលើកឡើងអំពីអវត្តមានភស្តុតាងស្តីពីវត្តមានជាផ្លូវការនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និង ប្រទេសវៀតណាម ដែលជាធាតុដ៏សំខាន់ដែលនាំឲ្យ មានការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។ ដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ការត្រួតពិនិត្យនៅក្នុងទិដ្ឋភាពនេះនៃបញ្ហាទាក់ទងនឹងអង្គសេចក្តី ជាពិសេសបញ្ហានេះនឹងនាំឲ្យជៀសមិនផុតដល់អង្គជំនុំជម្រះ និងរាល់ភាគីទាំងអស់ធ្វើការពិភាក្សាគ្នាអំពីធាតុផ្សេងៗនៃភស្តុតាងដែលបញ្ហានេះបានប៉ះពាល់ ទៅដល់ការសម្តែងឡើងអំពីអង្គសេចក្តីនៃដើមហេតុ។ដូច្នេះបញ្ហានេះ គឺធ្វើឡើងមុនកាលៈទេសៈ ដែលតម្រូវឲ្យអង្គជំនុំជម្រះបញ្ចូល ទៅក្នុងអង្គសេចក្តី។

៥០. ជាមួយគ្នានេះដែរ លោក ខៀវ សំផន នៅក្នុងពាក្យស្នើសុំរបស់ខ្លួនដែលផ្តោតសំខាន់ទៅលើអញ្ញត្រកម្មបឋមនៃសមត្ថកិច្ច ក៏បានលើកឡើងផងដែរ អំពីអសមត្ថកិច្ចជាបុគ្គលរបស់ អ.វ.ត.ក.។ ការត្រួតពិនិត្យលើការទទួលខុសត្រូវរបស់ ខៀវ សំផន ទោះបីជាលើកឡើងតាមរយៈអញ្ញត្រកម្មបឋមលើសមត្ថកិច្ចជាបុគ្គលបង្កើតយ៉ាងឧត្តមទៅលើបញ្ហានៃអង្គសេចក្តី ជាសជ្ឈន្តិកៈដែលទាក់ទងនឹងធម្មជាតិនៃអង្គហេតុដែលបានដាក់បន្ទុកទៅលើគុណវឌ្ឍន៍របស់គាត់។ ដូច្នេះ នៅក្នុងអង្គសេចក្តីក៏ដូចនៅក្នុងសំនុំរឿងទាំងមូល គឺនៅក្នុងអំឡុងពេលនៃដំណើរការសវនាការ ដូចជាការធ្វើសក្ខីកម្មទៅលើសាក្សី និងការពិភាក្សាដេញដោលលើភស្តុតាងដែលលើកឡើងនោះ អង្គជំនុំជម្រះអាចពិចារណាអំពីទំហំ និង វិសាលភាពនៃការទទួលខុសត្រូវរបស់ ខៀវ សំផន។

៥១. ដើម្បីសម្រេចឲ្យបាននូវគោលបំណងដ៏មានសារៈប្រយោជន៍ អង្គជំនុំជម្រះនឹងភ្ជាប់អញ្ញត្រកម្មនេះទៅអង្គសេចក្តីដូចសំនុំរឿង០០១ ដែរ។

## ២. ទឡ្ហីករណ៍ទី២ : ការផុតរលត់នៃបណ្ដឹងអាជ្ញា

### ២.១. ឧក្រិដ្ឋកម្មជាតិ

៥២. ទាក់ទងនឹងបញ្ហានេះ ដើមបណ្ដឹងរដ្ឋប្បវេណី យកតាមសេចក្ដីសម្រេចនៅថ្ងៃទី១៥ កុម្ភៈ ២០១១ ដែលកាត់សេចក្ដីទៅលើបណ្ដឹងឧទ្ធរណ៍ដែលលើកឡើងដោយ នួន ជា និង អៀង ធីរិទ្ធ។ តាមរយៈ កថាខ័ណ្ឌ១៧៦ បុរេអង្គជំនុំជម្រះ សន្និដ្ឋានដោយផ្ដល់ សមត្ថកិច្ចទៅដល់ អ.វ.ត.ក. ដើម្បីកាត់ទោសលើឧក្រិដ្ឋកម្មជាតិ។ អង្គបុរេជំនុំជម្រះបានសម្រេចថា មិនមាន ការរំលោភទៅលើគោលការណ៍នីត្យានុកូលភាពក្នុងបរិប័ទនេះទេ។

### ២.២. ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺ ណែវ ឆ្នាំ១៩៤៧ :

៥៣. ទាក់ទងនឹង បញ្ហាអាជ្ញាយុកាលនៃការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបើសិនជាយើងយោងទៅតាមមាត្រា ១ នៃកិច្ចព្រមព្រៀងទាក់ទងទៅនឹងភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មសង្គ្រាមឆ្នាំ ១៩៦៨ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ គឺគ្មានអាជ្ញាយុកាល។ បទបញ្ញត្តិនេះចែងថា «ឧក្រិដ្ឋកម្ម ខាងក្រោមនេះ គឺគ្មានអាជ្ញាយុកាល ដោយមិនគិតដល់កាលបរិច្ឆេទដែល ឧក្រិដ្ឋកម្មទាំង នេះបានកើតឡើងនោះទេ៖ ក. ឧក្រិដ្ឋកម្មសង្គ្រាម ដែលបានឲ្យនិយមន័យនៅ ក្នុងលក្ខន្តិកៈ នៃតុលាការយោធាអន្តរជាតិណូរមប៊ែរនៅថ្ងៃទី៨ សីហា ១៩៤៥ និង បានបញ្ជាក់អះអាង ដោយសេចក្ដីសម្រេច៣(I) និង ៩៥ (I) ដោយរដ្ឋសភារបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី១៣ កុម្ភៈ ១៩៤៦ និង ១១ ធ្នូ ១៩៤៦ ជាពិសេស "បទល្មើសធ្ងន់ធ្ងរ" ដែលមានចែង នៅក្នុងកិច្ចព្រមព្រៀងហ្សឺណែវនៅថ្ងៃទី១២ សីហា ១៩៤៩ ដើម្បីការពារជនរងគ្រោះដោយ សារសង្គ្រាម»។ លើសពីនេះទៀត ប្រសិនបើយើងបានអានសេចក្ដីសម្រេច **D427/3/15** តាមរយៈសេចក្ដីសម្រេចនេះ អង្គបុរេជំនុំជម្រះបានប្រកាសអំពីសមត្ថកិច្ច របស់អ.វ.ត.ក. ក្នុងការកាត់សេចក្ដីទៅលើឧក្រិដ្ឋកម្មអន្តរជាតិ[24]។ ដូច្នេះ យើងអាចសន្និដ្ឋាន បានថា ជនត្រូវចោទត្រូវតែទទួលបានការកាត់សេចក្ដីសម្រាប់ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុង ហ្សឺណែវ ឆ្នាំ១៩៤៩ ។

---

[24] ឯកសារយុត្តាធិការ D427/3/15 ចុងបញ្ចប់នៃកថាខ័ណ្ឌ ៩៩។

## IV- សេចក្ដីសន្និដ្ឋាន

៥៤. ដោយឈរលើអំណះអំណាងនៃហេតុផលជាបន្តបន្ទាប់ខាងលើរួចមក មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានស្នើ៖

អង្គជំនុំជម្រះសាលាដំបូង ប្រកាសអំពីអសមត្ថកិច្ចក្នុងការកាត់សេចក្ដីលើ៖

១. អញ្ញត្រកម្មបឋមស្ដីអំពី សមត្ថកិច្ចយុត្តាធិការ ការផុតរលត់នៃបណ្ដឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មជាតិ ដែលបានលើកឡើងដោយភាគីការពារលោក នួន ជា និង លោកស្រី អៀង ធីរិទ្ធ និងការផុតរលត់នៃបណ្ដឹងអាជ្ញាសម្រាប់ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលបានលើកឡើងដោយលោក អៀង សារី ដោយសម្អាងថាមានការរំលោភទៅលើវិធាន៧៧ (១៣) នៃវិធានផ្ទៃក្នុង ។

២. ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ខ្លួនមានសមត្ថកិច្ចក្នុងការកាត់សេចក្ដីម្ដងទៀតទៅលើបញ្ហាទាំងនេះ អង្គជំនុំជម្រះត្រូវប្រកាសថាការស្នើសុំដែលបានរៀបរាប់រួចមក និងអញ្ញត្រកម្មបឋមដែលបានលើកឡើងដោយលោក ខៀវ សំផន មិនអាចទទួលយកបានចំពោះការរំលោភទៅលើ គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអំពើដដែល (ne bis in idem) និង ប៉ះពាល់ទៅលើអាជ្ញាអស់ជំនុំ។

៥៥. បន្ថែមលើសពីនេះទៀត ស្នើអង្គជំនុំជម្រះសាលាដំបូងប្រកាសថា គ្រប់មធ្យោបាយនៃការស្នើសុំរបស់ក្រុមភាគីការពារទៅលើអញ្ញត្រកម្មបឋម អំពីសមត្ថកិច្ចយុត្តាធិការ និង ការផុតរលត់នៃបណ្ដឹងអាជ្ញាដែលបានលើកឡើងនោះមិនត្រឹមត្រូវតាមគតិ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលយក និងសម្រេចតាមសំណូមពរនៅក្នុងចម្លើយតបនេះដោយក្តីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ០៧ មីនា ២០១១ | **ពេជ អង្គ**<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | Elisabeth Simonneau-Fort<br>សហមេធាវីអន្តរជាតិនាំមុខ | ភ្នំពេញ | |
| | ម៉ុច សុវណ្ណារី<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | Martine JACQUIN<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | | |